ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍បូកសរុប

## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រចាំឆ្នាំ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៦-២០១៧



សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខែឧសភា ឆ្នាំ២០១៦



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍បូកសរុប

## ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រចាំឆ្នាំ២០១៥-២០១៦ និងទិសដៅការងារសម្រាប់ឆ្នាំ២០១៦-២០១៧

ម.ព.ឯ.ក AIDOC
Code: ____________
Date: ____________
Donated by: ____________



សន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខែឧសភា ឆ្នាំ២០១៦

# មាតិកា


I- សេចក្តីផ្តើម ........ 1

II- គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ........ 2

III- លទ្ធផលជារួម ........ 6

IV- លទ្ធផលតាមកម្មវិធី ........ 9

១. លទ្ធផលនៃផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ........ 9

២. ការបង្កើនផលិតភាពលើដំណាំកៅស៊ូ ........ 23

៣. ការជំរុញផលិតកម្មសត្វ និងសុខភាពសត្វ ........ 27

៤. លទ្ធផលនៃផ្នែកជលផល ........ 32

៥. លទ្ធផលនៃផ្នែកព្រៃឈើ ........ 35

៦. ការផ្តល់សេវាកម្មគាំទ្រ និងអភិវឌ្ឍន៍ធនធានមនុស្ស ........ 39

IV- បញ្ហាប្រឈម ........ 60

V- ទិសដៅអនុវត្តឆ្នាំ២០១៦-២០១៧ ........ 61

១. ផែនការផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម ........ 61

២ ផែនការផលិតកម្មដំណាំកៅស៊ូ ........ 62

៣ ផែនការផលិតកម្មសត្វនិងសុខភាពសត្វ ........ 63

៤ ផែនការផ្នែកជលផល ........ 64

៥ ផែនការផ្នែកព្រៃឈើ ........ 65

VI- សេចក្តីសន្និដ្ឋាន ........ 65

# របាយការណ៍បូកសរុប
# ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០១៥-២០១៦
# និងទិសដៅអនុវត្តឆ្នាំ២០១៦-២០១៧

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត **"យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨"** ដែលនៅតែចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាព ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសមធមិ ធានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការកែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនរួមមាន÷ ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្ម សំដៅបង្កើនទិន្នផលដំណាំនិងបន្សុំាការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនជីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាងនិងពង្រឹងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។ ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់អំពីការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្រប ក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិព្រៃឈើនិងជលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជកម្ម និងការបង្កើនចំណូលជាតិ។

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះ ផលិតកម្មដំណាំស្រូវមានការវិវឌ្ឍឈានឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិនិងអន្តរជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ ជាពិសេសការប្តូរទម្លាប់ពីការផលិតសម្រាប់ហូបចុកមកជាការផលិតសម្រាប់ពាណិជ្ជកម្ម។ ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្តាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្តូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធន៍ស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ជាពិសេស ការពង្រីកកាន់តែមានប្រសិទ្ធភាពលើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដីដើម្បីបង្កើនជីជាតិនិងទិន្នផល ការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗ ស្របតាមតម្រូវការទីផ្សារ។

ថ្មីៗនេះ ក្រសួងបានប្រកាសដាក់ឲ្យប្រើប្រាស់នូវឯកសារ "**គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា**" ដើម្បីឲ្យកសិករនិងសហគមន៍កសិករទទួលបាន និងប្រើប្រាស់ចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មបានល្អប្រសើរ។